**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សន្និសីទសារព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## បច្ចុប្បន្នភាពជំងឺកូវីដ-១៩ នៅកម្ពុជា
## គិតត្រឹមម៉ោង០៧:០០ព្រឹក នៃថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានបង្ហាញថា មិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី និងមិនមានអ្នកដែលជាសះស្បើយ ដោយអវិជ្ជមានតេស្តចំនួន ០២លើកនោះទេ។ ដូច្នេះ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា គិតត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ មានដូចខាងក្រោម៖

- **អ្នកព្យាបាលជាសះស្បើយ** សរុបចំនួនកើនដល់ **៧៧នាក់** (ស្មើនឹង ៦៣,១១% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១២នាក់ (ក្នុងនេះ មានទារកអាយុ ០៤ ខែ) ស្ត្រីជនជាតិបារាំង ១៣នាក់ បុរសជនជាតិម៉ាឡេស៊ី១០នាក់ បុរសជនជាតិខ្មែរ ៣២នាក់ និងស្ត្រីជនជាតិខ្មែរ ០៤នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។
- **អ្នកដែលកំពុងសម្រាកព្យាបាល** សរុបចំនួន ៤៥នាក់ (ស្ត្រី ១៨នាក់ និងបុរស ២៧នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១២២នាក់** (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។
- **ចំនួនវត្ថុសំណាកដែលបានធ្វើវិភាគសរុបមាន ៨.៩០៩ សំណាក** ដែលចំនួននេះ ប្រសិនបើគិតក្នុងចំណោមប្រជាជន០១លាននាក់ មាន ៥៥៦ សំណាកដែលបានធ្វើវិភាគ ដែលមានចំនួនច្រើនជាងបណ្តាប្រទេសក្នុងអាស៊ានមួយចំនួន ដូចជាប្រទេសភូមា មាន ២៦សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់ ប្រទេសឡាវ មាន ១៥៧សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់ ប្រទេសឥណ្ឌូណេស៊ី មាន ៧១ សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់ និងប្រទេសហ្វីលីពីន មាន ៣០៩សំណាក ក្នុងចំណោមប្រជាជនមួយលាននាក់។

ក្រសួងសុខាភិបាល សូមធ្វើការកត់សម្គាល់ថា **ការរកឃើញអ្នកមានវីរុសកូវីដ-១៩ នៅរាជធានីភ្នំពេញ** ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ នឹងអាចចូលជាករណីដែលចម្លងនៅក្នុងសហគមន៍ក្នុងទ្រង់ទ្រាយតូច ប្រសិន បើការស្រាវជ្រាវបន្តរបស់ក្រុមការងាររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល មន្ទីរសុខាភិបាលរាជធានីភ្នំពេញ រួមគ្នាជាមួយអង្គការសុខភាពពិភពលោក និងមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក រួមទាំងអាជ្ញាធរពាក់ព័ន្ធ អាចរកឃើញថា មិនមានប្រភពនៃការចម្លងវីរុសកូវីដ-១៩ ច្បាស់លាស់។ ក្រុមការងារនៅពេលនេះ កំពុងសកម្មក្នុងការស្រាវជ្រាវរុករកជាបន្តទៀត នូវអ្នកដែលមានហានិភ័យខ្ពស់ និងហានិភ័យទាប ដើម្បីចាត់ចែងការងារបន្តក្នុងការទប់ស្កាត់ការចម្លងចូលសហគមន៍ក្នុងទ្រង់ទ្រាយធំ កំប៉ុន្តែ តម្រូវឲ្យមានការចូលរួមពីបងប្អូនប្រជាពលរដ្ឋទាំងអស់



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible]

នៅក្នុងការអនុវត្តវិធានការទប់ស្កាត់នេះ។ ដូច្នេះ ក្រសួងសុខាភិបាលសូមធ្វើការអំពាវនាវ និងក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សូមប្រកាន់យកការផ្លាស់ប្តូរឥរិយាបទ ឬទម្លាប់របស់ខ្លួនជាចាំបាច់ នៅក្នុងដំណាក់កាលដែលវីរុសកូវីដ-១៩ ត្រូវបានរកឃើញក្នុងចំណោមភាគច្រើនលើសលុបជាជនបរទេស និងជនមកពីក្រៅប្រទេសជាបន្តបន្ទាប់ និងត្រូវអនុវត្តការដាក់ឲ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃសម្រាប់បុគ្គលចំណាកស្រុកដែលបានវិលត្រឡប់មកផ្ទះសម្បែងឬបានចូលមកក្នុងប្រទេស ហើយសំខាន់បំផុតនោះ ដើម្បីសុខភាពយើងទាំងអស់គ្នាជៀសផុតពីការចម្លងវីរុសកូវីដ-១៩ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវតែខិតខំអនុវត្តតាមការណែនាំ និងបទបញ្ជាប្រកបដោយគតិបណ្ឌិតនិងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការណែនាំផ្សេងៗទៀតរបស់ក្រសួងសុខាភិបាល ឲ្យបានខ្ជាប់ខ្ជួនជាទីបំផុត។

នៅក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរនេះ សូមបងប្អូននៅផ្ទះ កុំធ្វើដំណើរចល័ត (ជាបណ្តោះអាសន្ន) ត្រូវកម្រិតការចេញទៅក្រៅប្រសិនបើចាំបាច់ កុំប្រមូលផ្តុំគ្នាច្រើន ត្រូវអនុវត្តនូវគម្លាតសុវត្ថិភាពនៅទីកន្លែងមានមនុស្សច្រើន និងសូមរក្សាអនាម័យល្អ ដូចជាឧស្សាហ៍លាងដៃជាមួយសាប៊ូនិងទឹកស្អាត ឬអាល់កុល ឬទឹកដែលលាងដៃឲ្យបានញឹកញាប់ ប្រើប្រាស់ម៉ាស់ខ្ទប់មាត់និងច្រមុះពេលក្អកកណ្តាស់ជាដើម (សូមចូលមើលការណែនាំនានាដែលមានដាក់ផ្សាយនៅក្នុងទំព័រហ្វេសប៊ុកមកដែលមានឈ្មោះថា "ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា" និងតាមគេហទំព័រ www.cdcmoh.gov.kh ដើម្បីស្វែងយល់បន្ថែមទៀតអំពីវិធានការដែលត្រូវប្រកាន់យកមកអនុវត្ត សម្រាប់ទប់ស្កាត់ការចម្លង វីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតជាចាំបាច់។ ក្រសួងបានផលិតចេញជាសារអប់រំសុខភាពជាច្រើន ដែលបាន និងកំពុងផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម និងតាមទូរទស្សន៍នានាផងដែរ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រ ហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ ១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




ប្រភព៖ ក្រសួងសុខាភិបាល